**គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា**

**CAMBODIAN HUMAN RIGHTS ACTION COMMITTEE**

ADHOC - CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP- IDA
KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC - OUTREACH – PDP - PJJ - TASK FORCE - VIGILANCE
#09, St 330, Sangkat Boeung Keng Kang3, Khan Chamcar Mon, Phnom Penh, Cambodia, Tel/Fax: 023 301 415 E-mail: chrac@forum.org.kh


# សេចក្តីថ្លែងការណ៍

## អង្គការសង្គមស៊ីវិលគាំទ្រយន្តការត្រួតពិនិត្យជាសាកលយ៉ាងទៀងទាត់តាមកាលកំណត់ (UPR)

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ដែលជាសម្ព័ន្ធនៃអង្គការ-សមាគមមិនមែនរដ្ឋាភិបាល មានសមាជិកចំនួន២១ សូមសំដែងនូវការគាំទ្រយ៉ាងពេញលេញចំពោះយន្តការត្រួតពិនិត្យជាសាកលយ៉ាងទៀងទាត់តាមកាលកំណត់ (Universal Periodic Review/UPR) ដែលជាយន្តការតាមដានថ្មី របស់អង្គការសហប្រជាជាតិទៅលើវិស័យសិទ្ធិមនុស្សនៅក្នុងបណ្តារដ្ឋនីមួយៗដោយស្មើភាពគ្នា និង ដែលត្រូវធ្វើឡើងជាទៀតទាល់រៀងរាល់៤ឆ្នាំ ម្តង។

នៅក្រោមការត្រួតពិនិត្យនៃយន្តការថ្មីនេះ ប្រទេសកម្ពុជានឹងត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ ពិនិត្យអំពីការអនុវត្តន៍សិទ្ធិមនុស្សនៅក្នុងប្រទេសនេះ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ខាងមុខ។ នេះ គឺជាយន្តការត្រួតពិនិត្យជាលើកដំបូងសំរាប់បន្ថែមលើយន្តការនៃការតាមដានការអនុវត្តន៍សិទ្ធិមនុស្សផ្សេងៗទៀត។ ជាមួយនឹងការអបអរសាទរចំពោះការដែលប្រទេសកម្ពុជាដែលត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិដាក់ឱ្យស្ថិតក្រោមយន្តការនៃការត្រួតពិនិត្យជាសាកលយ៉ាងទៀងទាត់តាមកាលកំណត់នេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម ក៏សូមសំដែងនូវកង្វល់មួយចំនួនជុំវិញបញ្ហារំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដែលបានកើតឡើងកន្លងមក និងចេះតែបន្តកើតមានទៀតជាពិសេស គឺការរិតត្បិតសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការធ្វើបាតុកម្មដោយសន្តិវិធី, ការបណ្តេញចេញដោយបង្ខំ, ការប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីគៀបសង្កត់ទៅលើអ្នកដែលបញ្ចេញមតិជំទាស់, ការគំរាមកំហែងទៅលើសកម្មជនការពារសិទ្ធិមនុស្ស, និងបញ្ហារំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដទៃផ្សេងៗទៀត។

ដូចនេះ ឆ្លៀតឱកាសដែលមានព្រឹត្តិការណ៍សំខាន់នេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា មេត្តាយកចិត្តទុកដាក់ថែមទៀត ដើម្បីធានាឱ្យមានការអនុវត្តន៍ឱ្យបានពេញលេញនូវរាល់អនុសញ្ញា កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិមនុស្សដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន និងជារដ្ឋភាគីផងដែរ។ ម្យ៉ាងទៀត គណៈកម្មាធិការប្រព្រឹត្តិកម្ម ក៏សង្ឃឹមថារាជរដ្ឋាភិបាលកម្ពុជា នឹងទទួលយកនូវអនុសាសន៍នានារបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដើម្បីយកធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ស្របទៅតាមរដ្ឋធម្មនុញ្ញដែលបានថែងទទួលស្គាល់ និងលើកស្ទួយការគោរពសិទ្ធិមនុស្ស ផងដែរ។

*ភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩*


***សំរាប់ព័ត៌មានបន្ថែម សូមទាក់ទង:***

| | | |
|---|---|---|
| លោក **ហង្ស ឆាយា** | ប្រធានសំរបសំរួល CHRAC និង នាយកប្រតិបត្តិ KID | ទូរស័ព្ទលេខ: ០១២ ៨៦៩៩១០ |
| លោក **ធន សារាយ** | ប្រធានសមាគមអាដហុក | ទូរស័ព្ទលេខ: ០១៦ ៨៨០ ៥០៩ |
| លោក **សុក សំអឿន** | នាយកប្រតិបត្តិអង្គការ CDP | ទូរស័ព្ទលេខ: ០១២ ៩០១១៩៩ |
| លោកស្រី **ស៊ុន ចាន់សែន** | ប្រធានសមាគម KYA | ទូរស័ព្ទលេខ: ០១៧ ៧៨៨ ៩៥៥ |